**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:**១២៥៧ **អយក.**ហវ

ថ្ងៃ សុក្រ ៣រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥

**សូមគោរពជូន**

**ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

កម្មវត្ថុ ៖ សំណើសុំអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលការកត់ត្រាចំណាយពីអនុគណនី ៦១១២៨ ទៅអនុគណនី ៦២០២៨ សម្រាប់ប្រាក់ឧបត្ថម្ភមន្ត្រីអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីចុះតាមដានការងារបច្ចេកទេសនៅតាមសាលារៀនក្នុងវង្វង់ក្រុង ស្រុក ខណ្ឌ។

យោង ៖-អនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា

-ប្រកាសអន្តរក្រសួងលេខ ៣៤៥ សហវ.ប្រក.អថ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ

-លិខិតលេខ ៧៧៧៨ សហវ.អថ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជូន **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ កន្លងមក ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុវត្តចំណាយសម្រាប់ការចុះតាមដានការងារបច្ចេកទេសនៅតាមសាលារៀនក្នុងវង្វង់ក្រុង ស្រុក ខណ្ឌ ដោយផ្តល់ប្រាក់ឧបត្ថម្ភចំនួន៤០ ០០០រៀល(សែសិបពាន់រៀលគត់)ក្នុងម្នាក់ក្នុងមួយថ្ងៃ ហើយត្រូវកត់ត្រាមុខសញ្ញាចំណាយនេះនៅក្នុងអនុគណនី ៦១១២៨ (សោហ៊ុយក្នុងប្រទេសផ្សេងៗ) អនុលោមតាមស្មារតីនៃលិខិតលេខ៧៧៧៨ សហវ.អថ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ តាមស្មារតីប្រកាសអន្តរក្រសួងលេខ ៣៤៥ សហវ.ប្រក.អថ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ នៅត្រង់ជំពូកទី៣ ប្រការ៥ ទំព័រទី៦ គឺថវិកាគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡារបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងចំណាយមិនមែនបន្ទុកបុគ្គលិកក្នុងអនុគណនី ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត) តែមួយអនុគណនីប៉ុណ្ណោះសម្រាប់ចំណាយលើគ្រប់មុខសញ្ញាចំណាយ។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំអនុញ្ញាតជាគោលការណ៍ពី **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បានកែសម្រួលការកត់ត្រាពីអនុគណនី ៦១១២៨ ទៅ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

អនុគណនី ៦២០២៨ វិញ សម្រាប់ប្រាក់ឧបត្ថម្ភមន្ត្រីអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការចុះតាមដានការងារបច្ចេកទេសនៅតាមសាលារៀនដែលស្ថិតក្នុងរង្វង់ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យមានសង្គតិភាពទៅនឹងប្រកាសអន្តរក្រសួងលេខ៣៤៥ សហវ.ប្រក.អថ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្ររដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលការកត់ត្រាពីអនុគណនី ៦១១២៨ ទៅអនុគណនី ៦២០២៨ វិញ សម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៥ តទៅ ដោយសេចក្តីអនុគ្រោះ។

សូម ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គលេខាធិការដ្ឋាន

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-កាលប្បវត្តិ

-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ